TRANSPARENCY INTERNATIONAL
the global coalition against corruption

# សន្ទស្សន៍នៃការយល់ឃើញពីអំពើពុករលួយ ឆ្នាំ២០២២

## វិធីសាស្ត្រស្រាវជ្រាវ

បណ្ឌិត ផុនលី សិរីវិចិត្រ
ប្រធានកម្មវិធីស្រាវជ្រាវ និងអភិវឌ្ឍគម្រោង
អង្គការតម្លាភាពកម្ពុជា

ថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៣

# សន្ទស្សន៍នៃការយល់ឃើញពីអំពើពុករលួយ ឆ្នាំ២០២២ គឺជា៖

TRANSPARENCY INTERNATIONAL
the global coalition against corruption

| | |
|---|---|
| សន្ទស្សន៍ដែលផ្សំបញ្ចូលគ្នា | (ប្រភពទិន្នន័យ១៣ផ្សេងៗគ្នា) |
| មានលក្ខណៈជាសកល | (១៨០ប្រទេស/ដែនដី) |
| វាស់ស្ទង់ការយល់ឃើញ | (អ្នកជំនាញ/ធុរជន) |
| ពីអំពើពុករលួយ | (ការប្រើប្រាស់អំណាចខុសច្បាប់ ដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន) |
| នៅក្នុងវិស័យសាធារណៈ | (មន្ត្រី និងស្ថាប័នសាធារណៈ) |

# អ្វីដែលសន្ទស្សន៍ CPI ធ្វើការវាស់ស្ទង់

## ប្រភពទិន្នន័យទាំងអស់របស់យើងវាស់ស្ទង់អំពើពុករលួយក្នុងវិស័យសាធារណៈ ឬទិដ្ឋភាពជាក់លាក់មួយចំនួននៃអំពើពុករលួយក្នុងវិស័យសាធារណៈដូចជា៖

- សំណូក
- ការបង្វែរមូលនិធិសាធារណៈ
- ការប្រើប្រាស់តួនាទីដើម្បីផលប្រយោជន៍ឯកជន
- បក្ខពួកនិយមនៅក្នុងស្ថាប័នរដ្ឋ
- ឥទ្ធិពលរបស់ធុរជនទៅលើមន្ត្រីសាធារណៈ
- លទ្ធភាពរបស់រដ្ឋាភិបាលក្នុងការអនុវត្តយន្តការសុចរិតភាព
- ការផ្តន្ទាទោសប្រកបដោយប្រសិទ្ធភាពលើមន្ត្រីសាធារណៈដែលប្រព្រឹត្តអំពើពុករលួយ
- បែបបទរដ្ឋបាល និងការិយាធិបតេយ្យហួសហេតុ
- ការមានគ្រប់គ្រាន់នូវច្បាប់ស្តីពី ការបញ្ចេញព័ត៌មានហិរញ្ញវត្ថុ និងការបញ្ចៀសទំនាស់ផលប្រយោជន៍ និងសិទ្ធិទទួលបានព័ត៌មាន
- ការគាំពារផ្នែកច្បាប់ចំពោះបុគ្គលរាយការណ៍ អ្នកកាសែត និងអ្នកស៊ើបអង្កេត

# អ្វីដែលសន្ទស្សន៍ CPI មិនធ្វើការវាស់ស្ទង់

TRANSPARENCY INTERNATIONAL
the global coalition against corruption

## ដោយផ្អែកលើលក្ខណៈសម្បត្តិដែលមាននៅក្នុងប្រភពទិន្នន័យរបស់យើង ចំណុចខាងក្រោមនេះមិនត្រូវបានគ្របដណ្តប់នៅក្នុងសន្ទស្សន៍ CPI ទេ៖

- ការយល់ឃើញ ឬបទពិសោធន៍របស់ប្រជាពលរដ្ឋទាក់ទងនឹងអំពើពុករលួយ
- ការគេចពន្ធ
- លំហូរហិរញ្ញវត្ថុទុច្ចរិត
- អ្នកដែលអាចជំរុញឱ្យមានអំពើពុករលួយ (មេធាវី គណនេយ្យករ ទីប្រឹក្សាហិរញ្ញវត្ថុជាដើម)
- ការលាងលុយកខ្វក់
- អំពើពុករលួយក្នុងវិស័យឯកជន
- សេដ្ឋកិច្ចនិងទីផ្សារក្រៅផ្លូវការ

# វិធីសាស្ត្រ - ដំណាក់កាល

TRANSPARENCY INTERNATIONAL
the global coalition against corruption

**ដំហានទី១** ជ្រើសរើសប្រភពទិន្នន័យ

**ដំហានទី២** កំណត់មាត្រដ្ឋានទិន្នន័យឡើងវិញ

**ដំហានទី៣** គណនារកមធ្យមភាគ

**ដំហានទី៤** រាយការណ៍ពីភាពមិនច្បាស់លាស់

TRANSPARENCY INTERNATIONAL
the global coalition against corruption

# វិធីសាស្ត្រ - ប្រភពទិន្នន័យ

## អ្វីដែលធ្វើឱ្យប្រភពទិន្នន័យអាចប្រើបាន?

- ទំនុកចិត្តលើវិធីសាស្ត្រស្រាវជ្រាវ និងកិត្តិនាមរបស់ស្ថាប័នដែលធ្វើការស្រាវជ្រាវ
- ទិន្នន័យដែលមានគោលគំនិតស៊ីចង្វាក់គ្នា
- ការសិក្សាបែបបរិមាណវិស័យ
- អាចប្រៀបធៀបរវាងប្រទេសជាច្រើនបាន
- មានទិន្នន័យសម្រាប់ប្រៀបធៀបនឹងឆ្នាំផ្សេងទៀត

THE WORLD BANK
IBRD • IDA | WORLD BANK GROUP

FREEDOM HOUSE

The Economist INTELLIGENCE UNIT

World Justice Project

WORLD ECONOMIC FORUM

Bertelsmann Stiftung

# វិធីសាស្ត្រ - កំណត់មាត្រដ្ឋានទិន្នន័យឡើងវិញ



ប្តូរត្រឡប់ទិន្នន័យ (ក្នុងករណីចាំបាច់)

- តួលេខទាប = ពុករលួយខ្លាំង
- តួលេខខ្ពស់ = ស្អាតស្អំខ្លាំង

ធ្វើបមាណីយកម្មទិន្នន័យទៅជាមាត្រដ្ឋានសន្ទស្សន៍ CPI(0-១០០)

- **ធ្វើបមាណីយកម្មពីទិន្នន័យដើម**ទៅជាមាត្រដ្ឋានពិន្ទុពី 0 ដល់១០០
- សម្រួលរបាយទិន្នន័យឱ្យពិន្ទុអតិបរមាត្រឹម១០០ និងអប្បបរមាត្រឹម0

# វិធីសាស្ត្រ - កំណត់មាត្រដ្ឋានទិន្នន័យឡើងវិញ

TRANSPARENCY INTERNATIONAL
the global coalition against corruption



# វិធីសាស្រ្ត - គណនាមធ្យមភាគ

យ៉ាងហោចណាស់មានប្រភពទិន្នន័យចំនួន៣សម្រាប់ប្រទេសនីមួយៗ

គណនាមធ្យមភាគពិន្ទុ

ប្រភពទិន្នន័យនីមួយៗមានតម្លៃស្មើៗគ្នា



# វិធីសាស្ត្រ - គណនាមធ្យមភាគ

| ប្រទេស x | ពិន្ទុ |
|---|---|
| គម្រោងនៃភាពផ្សេងគ្នានៃប្រជាធិបតេយ្យ | ៧១ |
| ចំណាត់ថ្នាក់ហានិភ័យប្រចាំប្រទេសស្តីពីការយល់ដឹងជាសកល | ៦២ |
| គម្រោងយុត្តិធម៌ពិភពលោក | ៧១ |

$$\text{ពិន្ទុរបស់ប្រទេស X} = \frac{៧១+៦២+៧១}{៣}$$

$$= ៦៨$$

# វិធីសាស្រ្ត – រាយការណ៍ពីភាពមិនច្បាស់លាស់

**ដើម្បីកំណត់ភាពមិនច្បាស់លាស់នៅក្នុងពិន្ទុត្រូវ៖**

- រាយការណ៍ពីកម្រិតលម្អៀង
- គណនានូវចន្លោះជឿទុកចិត្ត ៩០%

# ការបកស្រាយលទ្ធផល

TRANSPARENCY INTERNATIONAL
the global coalition against corruption

## ពិន្ទុ៖

នៅលើមាត្រដ្ឋានពិន្ទុ ០-១០០ ដែល ០ មានន័យថាពុករលួយខ្លាំង ហើយ១០០គឺ ស្អាតស្អំខ្លាំង។

អនុញ្ញាតឱ្យមានការប្រៀបធៀបជាមួយនឹងពិន្ទុឆ្នាំមុនៗ (រវាងឆ្នាំ២០១២ ដល់២០២២)៖ ពិន្ទុរបស់ CPI ឆ្នាំ២០២២ អាចប្រៀបធៀបបានជាមួយពិន្ទុCPI រវាង១០ឆ្នាំមុន ហើយការប្រែប្រួលពិន្ទុអាចយកទៅបកស្រាយបាន។

## ចំណាត់ថ្នាក់៖

ក្នុងចំណោមប្រទេស/ដែនដីសរុប១៨០លើពិភពលោក ការប្រែប្រួលលេខរៀងអាចបណ្ដាលមកពី៖

ក) ការប្រែប្រួលពិន្ទុCPIសម្រាប់ប្រទេសណាមួយរវាងឆ្នាំមួយទៅឆ្នាំមួយទៀត

ខ) ការប្រែប្រួលពិន្ទុរបស់ប្រទេសផ្សេងទៀតដែលត្រូវបានបញ្ចូលនៅក្នុងសន្ទស្សន៍CPI

គ) ការបន្ថែមប្រទេស/ដែនដីទៅក្នុងសន្ទស្សន៍នេះ។

# ហេតុអ្វីនៅតែត្រូវការសន្ទស្សន៍CPI

សវនកម្មឯករាជ្យបានបញ្ជាក់ឡើងវិញថា សន្ទស្សន៍CPI គឺជាសូចនាករសកលដ៏សំខាន់មួយសម្រាប់ហេតុផលដូចខាងក្រោម៖

- វិសាលភាព
- ទំនុកចិត្តផ្នែកស្ថិតិ
- ភាពច្បាស់លាស់
- អព្យាក្រឹតភាព